# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**អាជ្ញាធរទន្លេសាប**

លេខ :...២៨១......អទស

ថ្ងៃ សុក្រ ៦ កើត ខែ ពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ២០២៥

## ជម្រាបជូន

- **ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តកំពង់ឆ្នាំង**
- **ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តពោធិ៍សាត់**
- **ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង**
- **ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ**
- **ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តសៀមរាប**
- **ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ**

**កម្មវត្ថុ ៖** សំណើសូមចូលរួមអនុវត្តដោយម៉ឺងម៉ាត់ក្នុងការចាត់វិធានការការពារ និងទប់ស្កាត់ការជីកស្តារប្រឡាយបូមទឹកពីតំបន់៣ ដើម្បីយកទៅប្រើប្រាស់ក្នុងតំបន់២ នៅក្នុងភូមិសាស្ត្រខេត្តទាំង៦ ជុំវិញតំបន់បឹងទន្លេសាប។

**យោង ៖** - អនុក្រឹត្យលេខ៨៣ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ របស់រាជរដ្ឋាភិបាល

- លិខិតលេខ១៨៨ សជណ.ដប ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

ន័យដូចមានចែងក្នុងកម្មវត្ថុ និងឯកសារយោងខាងលើ សូមជម្រាបជូន **ឯកឧត្តមអភិបាល** ជ្រាបថា ៖ ក្នុងទស្សនវិស័យយ៉ាងច្បាស់លាស់ និងស៊ីជម្រៅរបស់រាជរដ្ឋាភិបាលអាណត្តិទី៧ ស្របជាមួយនឹងស្មារតីយកចិត្តទុកដាក់ចូលរួមអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ជាពិសេស ប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានអំពាវនាវដល់ក្រសួង ស្ថាប័ន អាជ្ញាធរមូលដ្ឋាន និងកងកម្លាំងសមត្ថកិច្ចពាក់ព័ន្ធ ត្រូវអនុវត្តឱ្យបានតឹងរ៉ឹងបំផុតនូវវិធានការការពារ និងទប់ស្កាត់ផលប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ី និងប្រព័ន្ធត្រីទឹកសាបក្នុងបឹងទន្លេសាប ដើម្បីធានាបាននូវការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ ដូចជា ទឹក ដី ព្រៃលិចទឹក មច្ឆជាតិ និងជីវៈចម្រុះប្រកបដោយនិរន្តរភាព និងចីរភាព ដែលជាកត្តាចាំបាច់សម្រាប់ជីវភាពរស់នៅរបស់មនុស្ស និងសត្វ។

បច្ចុប្បន្នសកម្មភាពកាយជីកស្តារប្រឡាយ បូបទឹកពីតំបន់៣ ដើម្បីយកទៅប្រើប្រាស់ក្នុងតំបន់២ នៅក្នុងភូមិសាស្ត្រខេត្តទាំង៦ ជុំវិញតំបន់បឹងទន្លេសាប នៅតែបន្តកើតមាន ដែលបង្កឡើងដោយឈ្មួញធំៗនៅពីក្រោយ ដែលបាន និងកំពុងកើតមានឡើងនៅក្នុងតំបន់បឹងទន្លេសាប ជាពិសេសក្នុងរដូវបង្កបង្កើនផលស្រូវប្រាំងក្នុងតំបន់បឹងទន្លេសាប។ អាជ្ញាធរទន្លេសាប ក្នុងនាមជាសេនាធិការផ្ទាល់ឱ្យរាជរដ្ឋាភិបាល ក្នុងការសម្របសម្រួល ដឹកនាំគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប ស្នើឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តទាំង៦ ជុំវិញតំបន់បឹងទន្លេសាប (ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ) ចូលរួមអនុវត្តដោយម៉ឺងម៉ាត់ក្នុងការចាត់វិធានការការពារ និងទប់ស្កាត់ការកាយជីកស្តារប្រឡាយ បូបទឹកពីតំបន់៣ ដើម្បីយកទៅប្រើប្រាស់ក្នុងតំបន់២ នៅក្នុងភូមិសាស្ត្រខេត្តទាំង៦ ជុំវិញតំបន់បឹងទន្លេសាប ឬត្រូវស្នើសុំការអនុញ្ញាតទៅក្រសួង ស្ថាប័ន ជំនាញ (ក្រសួងធនធានទឹក និងឧតុនិយម និងអាជ្ញាធរទន្លេសាប) ពិនិត្យលក្ខណៈបច្ចេកទេសឱ្យបានត្រឹមត្រូវជាមុន ដើម្បីជៀសវាងការប៉ះពាល់ធ្ងន់ធ្ងរដល់ធនធាន

អគារលេខ: ៣៦៤.មហាវិថី ព្រះមុនីវង្ស,សង្កាត់ ផ្សារដើមថ្កូវ,ខណ្ឌ ចំការមន,រាជធានីភ្នំពេញ, ទូរស័ព្ទ / ទូរសារលេខ: (៨៥៥) ២៣ ៧២៧ ៤៥៤
# 364 Monivong Blvd., Phsar Deumthkov, Khan Chamkarmorn, Phnom Penh, Cambodia. Phone/Fax: (855) 23 727 454. Website: www.tonlesap.gov.kh

ជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ីធម្មជាតិ របស់បឹងទន្លេសាប ជាធនធានធម្មជាតិដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន ដែលត្រូវគ្រប់គ្រង ថែរក្សា ការពារ ទុកជាកេរមរតកសម្រាប់កូនចៅជំនាន់ក្រោយៗ។

អាជ្ញាធរទន្លេសាប នៅតែបន្តសហការជាមួយក្រុមការងារអន្តរក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋានក្នុងការចុះពិនិត្យ តាមដាន និងអធិការកិច្ចរាល់សកម្មភាពបទល្មើសដែលកើតមានឡើងនៅក្នុងតំបន់បឹងទន្លេសាប និងធ្វើសេចក្តីរាយការណ៍ជូនរាជរដ្ឋាភិបាល។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមអភិបាល** ពិនិត្យ និងមានវិធានការចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព តាមការគួរ។

សូម **ឯកឧត្តមអភិបាល** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**ប្រធាន**

**ចៅ_ជេដ្ឋា**

**<u>ចម្លងជូន</u> ៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងធនធានទឹក និងឧតុនិយម
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-ក្រសួងបរិស្ថាន
-អង្គភាពប្រឆាំងអំពើពុករលួយ
-ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម
"ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ